ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១៤១ ដនស/សផក

ថ្ងៃ ពុធ ៩រោច ខែ បុស្ស ឆ្នាំរោងឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២៥

## ជម្រាបជូន

- **ឯកឧត្តមអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន**
- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃមន្ទីរពិសោធន៍ជាតិសំណង់**
- **លោកប្រធានអង្គភាពក្រោមឱវាទក្រសួង**
- **លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត**

**កម្មវត្ថុ** ÷ ការអនុវត្តផែនការសវនកម្មផ្ទៃក្នុង និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៥

**យោង** ÷ - លិខិតលេខ៤៤០២ ដនស/នា.សផក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្ដីពីផែនការយុទ្ធសាស្ត្រនិងផែនការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល២០២៤-២០២៦

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកប្រធាន** ជ្រាបថា អនុលោមតាមផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល២០២៤-២០២៦ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនិងប្រសិទ្ធផលការងារនៅតាមបណ្ដាអង្គភាពថ្នាក់កណ្ដាលនិងថ្នាក់មន្ទីររាជធានី-ខេត្ត ឱ្យទទួលបាននូវសមិទ្ធកម្មថ្មីៗក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ពិសេសរក្សាបាននិរន្តរភាពនូវភាពជឿទុកចិត្តបាននៃឋវិកាសម្រេចបានការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដែលជាគន្លឹះរួមចំណែកគាំទ្រដល់ការអនុវត្ត«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឆ្នាំ២០២៣-២០២៨» របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវពង្រឹងមុខងារសវនកម្មរបស់ខ្លួនដោយរៀបចំផែនការសវនកម្មឱ្យកាន់តែមានប្រសិទ្ធភាពតាមបទបញ្ញត្តិជាធរមាន។

ចំពោះផែនការសវនកម្មប្រចាំឆ្នាំ២០២៥នេះ ត្រូវបានរៀបចំឡើងផ្អែកលើផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល២០២៤-២០២៦ ដែលប្រើប្រាស់«អភិក្រមផ្អែកលើដំណើរការមានហានិភ័យ» ដោយវិសាលភាពសវនកម្មត្រូវបានផ្អែកលើកម្រិតហានិភ័យនៃដំណើរការនីមួយៗនៅតាម អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដែលជាប្រធានកម្មវិធីនិងប្រធានអនុកម្មវិធី។ អនុលោមតាមនីតិវិធីនិងការគិតអង្គភាពថ្នាក់កណ្ដាលចំនួន០២ ថ្នាក់មន្ទីររាជធានី-ខេត្តចំនួន០៧ និងតាមដានអនុសាសន៍ចំនួន០៥ ត្រូវបានចាត់បញ្ចូលក្នុងផែនការ(ដូចមានជូនភ្ជាប់ជាមួយ)។

ការធ្វើសវនកម្មនៅថ្នាក់កណ្ដាលនិងថ្នាក់មូលដ្ឋាន ជារួមគឺផ្ដោតជាសំខាន់ទៅលើភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងការប្រើប្រាស់ភាពអនុលោមតាមផែនការនីតិវិធី បទដ្ឋានច្បាប់ ភាពត្រឹមត្រូវ និងទាន់ពេលនៃការកត់ត្រាចំណូល-ចំណាយ ប្រតិបត្តិការ និងរបាយការណ៍ រួមទាំងការជួយកំណត់ហានិភ័យ ផ្ទៀងផ្ទាត់



អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

វឌ្ឍនភាពនៃការអនុវត្តផែនការ សកម្មភាពក្នុងកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរក្សាសុវត្ថិភាពនៃទ្រព្យសម្បត្តិ ការសន្សំសំចៃ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងបច្ចេកទេស និងការទទួលខុសត្រូវឱ្យមានតុល្យភាព សង្គតិភាព និងភាពប្រទាក់ក្រឡាការងារផ្ទៃក្នុងក្រសួង ដើម្បីជាមូលដ្ឋានសម្រាប់ឈានទៅសម្រេចជោគជ័យក្នុងរយៈពេលវែង ជានាឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចអនុវត្តគោលនយោបាយ និងគ្រប់គ្រងការប្រើប្រាស់ថវិកាជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដោយឡែកការចុះតាមដានអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមក នឹងត្រូវធ្វើក្នុងចន្លោះពីបីទៅប្រាំមួយខែក្រោយពីចុះធ្វើសវនកម្ម ដើម្បីពិនិត្យមើលការកែលម្អតាមអនុសាសន៍ឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងច្បាស់លាស់ ។

ដើម្បីសម្រេចគោលដៅនេះ សវនករត្រូវបំពេញការងារសវនកម្មដោយឯករាជ្យស្របតាមស្តង់ដា និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផ្ទៃក្នុង ផ្តល់អនុសាសន៍កែលម្អឱ្យអង្គភាពសម្រេចបាននូវគោលដៅដែលកំណត់។ ការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញចំពោះការអនុវត្តតាមអនុសាសន៍ នឹងត្រូវបានសម្រេចដោយថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងត្រូវចុះធ្វើសវនកម្មតាមផែនការ តាមករណីចាំបាច់ តាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកប្រធាន** ចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុង ឆ្នាំ២០២៥ នេះ ឱ្យបានសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

សូម **ឯកឧត្តម លោកប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

ចម្លងជូន÷
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ-កាលប្បវត្តិ